# ផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុកម្ពុជា ២០១៤-២០២៣

ឯកសារសង្ខេបទី ១

## ១. ការព្យាករណ៍អាកាសធាតុ

- សីតុណ្ហភាពមធ្យមប្រចាំខែនឹងកើនឡើងចន្លោះពី០,០១៣°C ដល់ ០,០៣៦°C ក្នុងមួយឆ្នាំៗ រហូតដល់ឆ្នាំ២០៩៩។
- ការព្យាករណ៍នានាបានបញ្ជាក់ថា ជារួមកម្ពស់ទឹកភ្លៀងមធ្យមប្រចាំឆ្នាំនឹងកើននៅប្រទេសកម្ពុជា។
- កម្ពស់ទឹកសមុទ្រនៅក្នុងតំបន់ នឹងកើនឡើងទៅតាមកម្រិត រហូតដល់ឆ្នាំ២០៩០ ធៀបនឹងឆ្នាំ១៩៨០-១៩៩៩ កម្ពស់ទឹកសមុទ្រនឹងកើនឡើងពី
  - ◊ ០,១៨-០,៤៣ម. នៅក្រោមសេណារីយ៉ូអត្រាបញ្ចេញឧស្ម័នកម្រិតទាប (SRES B1)
  - ◊ ០,២១-០,៥២ម. នៅក្រោមសេណារីយ៉ូអត្រាបញ្ចេញឧស្ម័នកម្រិតមធ្យម (SRES A1B)
  - ◊ ០,២៣-០,៥៦ម. នៅក្រោមសេណារីយ៉ូ អត្រាបញ្ចេញឧស្ម័នកម្រិតខ្ពស់ (SRES A2)។

  នេះមានន័យថា ប្រសិនអត្រាកំណើនកម្ពស់ទឹកសមុទ្រនឹងមាន០,៥៦ម. គឺអាចបង្កឱ្យមានការជន់លិចជាអចិន្ត្រៃយ៍លើផ្ទៃដីទំហំប្រមាណ២៥.០០០ ហិកតា នៅតាមតំបន់ឆ្នេរកម្ពុជា ក្នុងរយៈពេល៩០ឆ្នាំខាងមុខ។

**ឥទ្ធិពល**

- ទិន្នផលស្រូវនឹងថយចុះ១០% សម្រាប់កំណើនសីតុណ្ហភាព ១°C ធៀបនឹងសីតុណ្ហភាពអប្បបរមានៅរដូវដាំដុះ (ពេលយប់)។
- នៅរដូវវស្សានឹងមានភ្លៀងច្រើនជាងមុន ដោយឡែកនៅរដូវប្រាំងវិញមានសភាពស្ងួតហែងចំពោះខេត្តមានរយៈកម្ពស់ខ្ពស់។
- ឆ្នេរសមុទ្រកម្ពុជា នឹងងាយរងគ្រោះដោយសារកំណើនកម្ពស់ទឹកសមុទ្រ និងផលប៉ះពាល់ធ្ងន់ធ្ងរពីខ្យល់ព្យុះទីហ្វុងកាន់តែញឹកញាប់។
- តំបន់ឆ្នេរនឹងរងឥទ្ធិពលពីខ្យល់ព្យុះស៊ីក្លូន ចំណែកតំបន់ទំនាបកណ្ដាលនឹងរងគ្រោះដោយសារទឹកជំនន់។

ផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុកម្ពុជា (ផ.យ.ប.អ.ក.) ២០១៤-២០២៣ ត្រូវបានរៀបចំឡើង ដើម្បីដោះស្រាយបញ្ហាប្រែប្រួលអាកាសធាតុ តាមរយៈវិធានការបន្សាំ ការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ និងការអភិវឌ្ឍដោយបញ្ចេញកាបូនតិច។ ផែនការយុទ្ធសាស្ត្រនេះ គឺជាឯកសារគោលនយោបាយជាតិ ដែលបានដាក់ឱ្យប្រើប្រាស់ជាផ្លូវការ នៅខែវិច្ឆិកា ឆ្នាំ២០១៣។

## ២. សង្ខេប ផ.យ.ប.អ.ក. ២០១៤-២០២៣

### ចក្ខុវិស័យ

**កម្ពុជាអភិវឌ្ឍឆ្ពោះទៅរកសង្គមមួយដែលបៃតង បញ្ចេញកាបូនតិច ធន់នឹងការប្រែប្រួលអាកាសធាតុ សមធម៌ ចីរភាព និងពឹងផ្អែកលើចំណេះដឹងជាគោល។**

### គោលបំណង

១. កាត់បន្ថយភាពងាយរងគ្រោះរបស់ប្រជាជន ជាពិសេសក្រុមអ្នកដែលងាយរងគ្រោះបំផុត និងប្រព័ន្ធសំខាន់ៗ (ធម្មជាតិ និងសង្គម) បណ្ដាលមកពីផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ។

២. បង្វែរទៅរកមាគ៌ាអភិវឌ្ឍបៃតង តាមរយៈការលើកកម្ពស់ការអភិវឌ្ឍបញ្ចេញកាបូនតិច និងបច្ចេកវិទ្យាពាក់ព័ន្ធ។

៣. លើកកម្ពស់ការយល់ដឹង និងការចូលរួមរបស់សាធារណជនក្នុងការឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ។

### ទិសដៅជាយុទ្ធសាស្ត្រ (ទ.យ.)

- **ទ.យ. ២៖** កាត់បន្ថយភាពងាយរងគ្រោះតាមវិស័យ តំបន់ យេនឌ័រ និងសុខភាព នៅចំពោះមុខផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ។
- **ទ.យ. ៣៖** លើកកម្ពស់ ភាពធន់នឹងអាកាសធាតុនៃប្រព័ន្ធអេកូឡូស៊ីសំខាន់ៗ (បឹងទន្លេសាប ទន្លេមេគង្គ តំបន់ឆ្នេរ តំបន់ខ្ពង់រាប ។ល។) ជីវៈចម្រុះ តំបន់ការពារធម្មជាតិ និងតំបន់បេតិកភណ្ឌវប្បធម៌។
- **ទ.យ. ៦៖** លើកកម្ពស់ការចូលរួម និងកិច្ចគាំពារសង្គមបែបបន្សាំនឹងការប្រែប្រួលអាកាសធាតុ ដើម្បីកាត់បន្ថយការបាត់បង់ និងខូចខាត។
- **ទ.យ. ១៖** លើកកម្ពស់ភាពធន់នឹងអាកាសធាតុ តាមរយៈការធ្វើឱ្យប្រសើរឡើងនូវសន្តិសុខស្បៀង ទឹក និងថាមពល។
- **ទ.យ. ៤៖** លើកកម្ពស់ការកសាងផែនការ និងបច្ចេកវិទ្យាបញ្ចេញកាបូនតិច ដើម្បីគាំទ្រដល់ការអភិវឌ្ឍដោយចីរភាព។
- **ទ.យ. ៥៖** កែលម្អសមត្ថភាព ចំណេះដឹង និងការយល់ដឹងសម្រាប់ឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ។
- **ទ.យ. ៧៖** ពង្រឹងស្ថាប័ន និងក្របខ័ណ្ឌការងារសម្របសម្រួលសម្រាប់ឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុថ្នាក់ជាតិ។
- **ទ.យ. ៨៖** ពង្រឹងកិច្ចសហការ និងចូលរួមយ៉ាងសកម្មនៅក្នុងកិច្ចខិតខំប្រឹងប្រែងឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុនៅថ្នាក់តំបន់ និងពិភពលោក។

## ៣. ដំណាក់កាលសម្រាប់អនុវត្ត ផ.យ.ប.អ.ក.

| | |
|---|---|
| **រយៈពេលខ្លី** (២០១៣-២០១៤) | ▪ រៀបចំយន្តការចាត់ចែងស្ថាប័ន និងហិរញ្ញវត្ថុ<br>▪ កសាងផែនការសកម្មភាពលម្អិត និងចាត់អាទិភាព (២០១៤-២០១៨) ដោយក្រសួង-ស្ថាប័នពាក់ព័ន្ធ<br>▪ រៀបចំក្របខ័ណ្ឌហិរញ្ញប្បទានប្រែប្រួលអាកាសធាតុ<br>▪ បង្កើតក្របខ័ណ្ឌពិនិត្យ តាមដាន និងវាយតម្លៃ<br>▪ បង្កើតក្របខ័ណ្ឌច្បាប់ ស្តីពី ការប្រែប្រួលអាកាសធាតុ។ |
| **រយៈពេលមធ្យម** (២០១៤-២០១៨) | ▪ រៀបចំយន្តការទទួលបានមូលនិធិបន្ស៊ាំ និងមូលនិធិអាកាសធាតុបៃតង<br>▪ ស្រាវជ្រាវ និងការគ្រប់គ្រងចំណេះដឹង<br>▪ អភិវឌ្ឍសមត្ថភាព<br>▪ បញ្ជ្រាបការប្រែប្រួលអាកាសធាតុនៅតាមកម្រិតថ្នាក់នៃវិស័យនានា<br>▪ ប្រតិបត្តិប្រព័ន្ធត្រួតពិនិត្យ និងវាយតម្លៃ និងគ្រប់គ្រងទិន្នន័យ<br>▪ ចាប់ផ្តើម និងពង្រីកជាបណ្តើរៗនូវគម្រោងថវិកា និងនីតិវិធីនៃការអនុវត្ត<br>▪ បង្កើតស្ថាប័នសមស្របមួយ ដែលមានសមត្ថភាពគ្រប់គ្រាន់ និងលក្ខណៈសម្បត្តិពេញលេញ ដែលអាចបានការទទួលស្គាល់ជាផ្លូវការ និងមានសិទ្ធិទទួលយកថវិកាដោយផ្ទាល់ពីមូលនិធិបន្ស៊ាំ និងមូលនិធិអាកាសធាតុបៃតង។ |
| **រយៈពេលវែង** (២០១៩-២០២៣) | ▪ ពង្រីកសកម្មភាពជោគជ័យ ដែលសម្រេចបានកន្លងមក និងបន្តបញ្ជ្រាបការប្រែប្រួលអាកាសធាតុទៅក្នុងកម្មវិធីនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ<br>▪ បង្កើនការប្រើប្រាស់មូលនិធិគាំទ្រ សម្រាប់កម្មវិធីជាតិ រួមទាំងការផ្តល់មូលនិធិសម្រាប់វិធានការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ តាមរយៈរដ្ឋបាលនៅថ្នាក់ក្រោមជាតិ។ |

### បញ្ហាអន្តរវិស័យ

- យេនឌ័រ កិច្ចគាំពារសង្គម ការស្រាវជ្រាវ ការលើកកម្ពស់ការយល់ដឹង ការប្រាស្រ័យទាក់ទង M&E ហិរញ្ញប្បទានអាកាសធាតុ និងការគ្រប់គ្រងចំណេះដឹង

### ភាពជាដៃគូ

- ដៃគូអភិវឌ្ឍន៍ អង្គការមិនមែនរដ្ឋាភិបាល (ទាំងជាតិ និងអន្តរជាតិ) វិស័យឯកជន សហគមន៍មូលដ្ឋាន និងអង្គការដទៃទៀត

## ៤. ការផ្តល់ធនធានហិរញ្ញវត្ថុ

យន្តការហិរញ្ញប្បទានប្រែប្រួលអាកាសធាតុរបស់ជាតិត្រូវគាំទ្រវិធីសាស្ត្រជាយុទ្ធសាស្ត្រនេះ តាមរយៈការអនុវត្តគោលការណ៍នានាដូចតទៅ ៖

⇒ **ការបន្ស៊ីគ្នាជាមួយអាទិភាពជាតិ** តាមរយៈការផ្តល់មូលនិធិសម្រាប់កម្មវិធី និងគម្រោងនានា ដែលមានចែងនៅក្នុងផែនការសកម្មភាពនៅក្រោម **ផ.យ.ប.អ.ក.**។

⇒ **ការប្រមូលផ្តុំធនធាន** ដើម្បីកាត់បន្ថយថ្លៃចំណាយប្រតិបត្តិការ។

⇒ **ការប្រើប្រាស់ប្រព័ន្ធ និងនីតិវិធីរបស់ជាតិ** ដែលមូលនិធិជាតិប្រែប្រួលអាកាសធាតុមួយ អាចនឹងត្រូវបង្កើតឡើង ដើម្បីទទួលការគាំទ្រហិរញ្ញវត្ថុពីក្នុង និងក្រៅប្រទេស ហើយវិភាជន៍មូលនិធិនេះទៅគម្រោងប្រែប្រួលអាកាសធាតុដែលមានអាទិភាពខ្ពស់។

⇒ **ការផ្ទេរអំណាចទៅថ្នាក់ក្រោម** ដោយធានាថាធនធានថវិកាត្រូវស្ថិតនៅក្រោមការចាត់ចែងរបស់ក្រសួងពាក់ព័ន្ធ និងរដ្ឋបាលមូលដ្ឋានដែលពាក់ព័ន្ធ។ ចំណែក **គ.ជ.គ.ប.អ.** ជាអ្នកសម្របសម្រួលហិរញ្ញប្បទានប្រែប្រួលអាកាសធាតុ ដើម្បីបន្ស៊ីជាមួយអាទិភាពនានារបស់ជាតិ។

## ៥. ការពិនិត្យតាមដាន និងវាយតម្លៃ (M&E)

**ផ.យ.ប.អ.ក.** ទទួលស្គាល់ពីសារៈសំខាន់នៃការដោះស្រាយបញ្ហាប្រឈមតាមរយៈការបង្កើតក្របខ័ណ្ឌជាតិមួយសម្រាប់ M&E លើការងារប្រែប្រួលអាកាសធាតុ។ គោលបំណងរបស់ក្របខ័ណ្ឌជាតិសម្រាប់ M&E លើការប្រែប្រួលអាកាសធាតុ រួមមាន៖

⇒ វាស់ស្ទង់ប្រសិទ្ធភាពនៃកិច្ចប្រឹងប្រែងក្នុងការងារបន្ស៊ាំនឹងការប្រែប្រួលអាកាសធាតុ។

⇒ ពិនិត្យតាមដានសកម្មភាពកាត់បន្ថយការប្រែប្រួលអាកាសធាតុ និងគោលនយោបាយអភិវឌ្ឍន៍ដែលបញ្ចេញកាបូនតិច។

⇒ ចងក្រងភស្តុតាង និងមេរៀននានា ដើម្បីជាមូលដ្ឋានសម្រាប់ការកសាងគោលនយោបាយទៅអនាគត។

⇒ សម្រួលឱ្យមានសមាហរណកម្មស៊ីសង្វាក់គ្នានៃ M&E លើការប្រែប្រួលអាកាសធាតុនៅក្នុងការកសាងផែនការអភិវឌ្ឍន៍ជាតិ និងវិស័យសំខាន់ៗ។

⇒ ផ្តល់ព័ត៌មានដែលចាំបាច់ ក្នុងការបំពេញកាតព្វកិច្ចធ្វើរបាយការណ៍ក្រោមអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ និងដៃគូអភិវឌ្ឍន៍។

មីនា ២០១៤

ផលិតដោយ គណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ (គ.ជ.គ.ប.អ.)
គាំទ្រថវិកាដោយ កម្មវិធីសម្ព័ន្ធភាពប្រែប្រួលអាកាសធាតុកម្ពុជា (CCCA)
ក្រសួងបរិស្ថាន អគារលេខ ៤៨ វុក្ខវិថីព្រះសីហនុ រាជធានីភ្នំពេញ ទូរស័ព្ទ/ទូរសារ៖ (៨៥៥-២៣) ២១៨ ៣៧០
អ៊ីម៉ែល៖ admin@camclimate.org.kh គេហទំព័រ៖ www.camclimate.org.kh

CAMBODIA CLIMATE CHANGE ALLIANCE
Implemented by: Ministry of Environment
Supported by: European Union, UNDP, Danida, SWEDEN

# CAMBODIA CLIMATE CHANGE STRATEGIC PLAN 2014 – 2023

Fact Sheet 1

## 1. KEY FACTS ON CLIMATE PROJECTION

- Mean monthly temperatures will increase between 0.013°C and 0.036°C per year by 2099.
- Mean annual rainfall indicates an increase in rainfall for Cambodia.
- Sea levels in the region are projected to rise under various scenarios by 2090 relative to 1980 – 1999:
  - ◊ 0.18 - 0.43 m under low emission scenarios (SRES B1),
  - ◊ 0.21 – 0.52 m under medium emission scenario (SRES A1B),
  - ◊ 0.23 – 0.56 m under high emission scenario (SRES A2). This rate would cause permanent inundation of about 25,000 ha of coastal Cambodia within 90 years.

***Implications***

- Rice grain yield will decline by 10% for each 1°C increase in growing-season (night temperature).
- Rainfall will get higher in the provinces at higher elevation during the wet season, but it will get drier during the dry season.
- The coastline is vulnerable to sea-level rises and the severe impacts of more frequent typhoons.
- Coastal zones would be affected by tropical cyclones while the central plains would experience seasonal flooding.

***Cambodia Climate Change Strategic Plan (CCCSP) 2014-2023 is designed to ensure strategic cohesion to address a wide range of climate change issues concerning adaptation, GHG mitigation, and low-carbon development.***

***CCCSP is the first ever comprehensive national policy document responding to climate change issues launched in November 2013.***

## 2. SUMMARY OF CCCSP 2014-2023

**VISION**

Cambodia develops towards a green, low-carbon, climate-resilient, equitable, sustainable and knowledge-based society.

**GOALS**

**Goal 1:** Reducing vulnerability to climate change impacts of people, in particular the most vulnerable, and critical systems (natural and societal).

**Goal 2:** Shifting towards a green development path by promoting low-carbon development and technologies.

**Goal 3:** Promoting public awareness and participation in climate change response actions.

**STRATEGIC OBJECTIVE (S.O.)**

Goal 1:

- **S.O. 2:** Reduce sectoral, regional, gender vulnerability and health risks to climate change impacts.
- **S.O. 3:** Ensure climate resilience of critical ecosystems (Tonle Sap Lake, Mekong River, coastal ecosystems, highlands, etc.), biodiversity, protected areas and cultural heritage sites.
- **S.O. 6:** Promote adaptive social protection and participatory approaches in reducing loss and damage due to climate change.

Goal 2:

- **S.O. 1:** Promote climate resilience through improving food, water and energy security.
- **S.O. 4:** Promote low-carbon planning and technologies to support sustainable development.

Goal 3:

- **S.O. 5:** Improve capacities, knowledge and awareness for climate change responses.
- **S.O. 7:** Strengthen institutions and coordination frameworks for national climate change responses.
- **S.O. 8:** Strengthen collaboration and active participation in regional and global climate change processes.

## 3. IMPLEMENTATION PHASES

| | |
|---|---|
| ***Immediate term*** (2013 – 2014) | ▪ Institutional and financial arrangements;<br>▪ Develop action plans (2014-2018) by concerned line ministries and agencies;<br>▪ Develop a Climate Change Financing Framework;<br>▪ Establish a national M&E framework;<br>▪ Develop a Climate Change Legal Framework. |
| ***Medium term*** (2014 – 2018) | ▪ Establish a nationally accredited mechanism for the Adaptation Fund and Green Climate Fund;<br>▪ Research and knowledge management activities;<br>▪ Develop capacity;<br>▪ Mainstream climate change at various sectoral levels;<br>▪ Operationalize M&E and data management system;<br>▪ Increase the climate change finance for national and sub-national planning, budgeting and implementation modalities;<br>▪ Establish appropriate institution with sufficient capacity and full credibility for direct access to the Adaptation Fund and Green Climate Fund. |
| ***Long term*** (2019 – 2023) | ▪ Scale-up successful pilots and carry on with the mainstreaming of climate change at national and sub-national levels;<br>▪ Increase the use of budget support for national programmes, including implementation of climate change response measures through sub-national administrations. |

**Cross-Cutting Issue:**

- Gender, Social Protection, Research, Education Awareness, Communication, M&E, Climate Financing, Knowledge Management

**Partnership:**

- Development Partners, NGOs, Private Sectors, Local Communities, Organizations

## 4. FINANCING RESOURCES

National climate change financing mechanisms shall support this strategic approach through the application of the following principles:

⇒ **Alignment with national priorities** through funding programmes and projects identified in action plans under the CCCSP.

⇒ **Having pooled resources mechanism** in order to minimize transaction costs.

⇒ **Use of national systems and procedures** that a national climate fund may be set up to receive domestic and external financial support and allocate it to high priority climate change projects.

⇒ **Subsidiarity** by ensuring financing mechanism are managed by the most qualified line ministries or local governments while climate change financing will need to be coordinated by the NCCC.

## 5. MONITORING AND EVALUATION (M&E)

The CCCSP recognises the importance of addressing these challenges by establishing a national framework for M&E of climate change. The aim of the national framework for M&E of climate change is to:

⇒ Measure adaptation efforts in keeping development on track in a changing climate.

⇒ Monitor climate change mitigation actions and low -carbon development policies.

⇒ Generate evidence and lessons as a basis for future policy development.

⇒ Facilitate the coherent integration of M&E of climate change in national development planning and key sectors.

⇒ Provide the information required to fulfil the reporting obligations towards the UNFCCC and development partners.

***March 2014***

**Produced by National Climate Change Committee (NCCC)**
Financially supported by Cambodia Climate Change Alliance (CCCA)
Ministry of Environment, # 48, Samdech Preah Sihanouk Blvd., Phnom Penh, Cambodia
Phone/Fax: (855-23) 218 370, Email: admin@camclimate.org.kh
**Obtain full fact sheets from www.camclimate.org.kh**

CAMBODIA CLIMATE CHANGE ALLIANCE
Implemented by: Supported by:
Ministry of Environment European Union UNDP Danida SWEDEN

# កាត់បន្ថយភាពងាយរងគ្រោះរបស់ប្រជាជនបណ្ដាល មកពីផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ

## តួលេខពិតសំខាន់ៗ នៃភាពងាយរងគ្រោះ

កម្ពុជា ជាប្រទេសងាយរងគ្រោះបំផុត ពីការប្រែប្រួលអាកាសធាតុ ដោយសារសមត្ថភាពបន្សាំនៅមានកម្រិតទាបៈ

- មានភាពប្រឈមខ្ពស់ទៅនឹងគ្រោះមហន្តរាយ ហើយយន្តការដោះស្រាយនៅមានកម្រិតៈ
  - ប្រជាជនដែលបានប្រឈមនឹងទឹកជំនន់ៈ ១,៧លាននាក់ (១២,២%) នៃប្រជាជនកម្ពុជា។
  - ការបាត់បង់ និងខូចខាតដោយសារព្យុះកេតសាណា ឆ្នាំ២០០៩ៈ ១៣២លានដុល្លារ និងបាត់បង់ជីវិត ៤៣នាក់។
  - ការបាត់បង់ និងខូចខាតដោយសារគ្រោះទឹកជំនន់ ឆ្នាំ២០១១ៈ ៥២០លានដុល្លារ និងបាត់បង់ជីវិត ២៥០នាក់។
  - ការបាត់បង់ និងខូចខាតដោយសារគ្រោះទឹកជំនន់ ឆ្នាំ២០១៣ៈ ៣៥៦លានដុល្លារ និងបាត់បង់ជីវិត ១៦៨នាក់។
- ៤៣% នៃឃុំសរុប ជាឃុំដែលងាយរងគ្រោះបំផុត។
- គ្មាននីតិវិធីច្បាស់លាស់សម្រាប់បញ្ជ្រាបការប្រែប្រួលអាកាសធាតុទៅក្នុងផែនការអភិវឌ្ឍន៍ជាតិ។
- សមត្ថភាពស្ថាប័នជាតិទទួលបន្ទុកការប្រែប្រួលអាកាសធាតុ និងការចូលរួមរបស់អ្នកពាក់ព័ន្ធនៅមានកម្រិត។
- ប្រជាពលរដ្ឋមានសមត្ថភាពបន្សាំទាប។




*ប្រភព៖ EEPSEA, 2010*

*ផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុកម្ពុជា (ផ.យ.ប.អ.ក.) ២០១៤-២០២៣ ត្រូវបានរៀបចំឡើង ដើម្បីដោះស្រាយបញ្ហាប្រែប្រួលអាកាសធាតុ តាមរយៈវិធានការបន្សាំ ការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ និងការអភិវឌ្ឍដោយបញ្ចេញកាបូនតិច។*

*ផ.យ.ប.អ.ក. គឺជាឯកសារគោលនយោបាយជាតិក្នុងក្របខ័ណ្ឌយុទ្ធសាស្ត្រប្រទាក់ក្រឡាគ្នាឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ ដែលបានដាក់ឱ្យប្រើប្រាស់ជាផ្លូវការ នៅខែវិច្ឆិកា ឆ្នាំ២០១៣។*

**ផ.យ.ប.អ.ក. ២០១៤-២០២៣**

**ចក្ខុវិស័យ**

**កម្ពុជាអភិវឌ្ឍឆ្ពោះទៅរកសង្គមមួយដែលបៃតង បញ្ចេញកាបូនតិច ធន់នឹងការប្រែប្រួលអាកាសធាតុ សមធម៌ ចីរភាព និងពឹងផ្អែកលើចំណេះដឹងជាគោល។**

**គោលបំណងទី ១៖** កាត់បន្ថយភាពងាយរងគ្រោះរបស់ប្រជាជន ជាពិសេសក្រុមអ្នកដែលងាយរងគ្រោះបំផុត និងប្រព័ន្ធសំខាន់ៗ (ធម្មជាតិ និងសង្គម) បណ្ដាលមកពីផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ។

**ទិសដៅយុទ្ធសាស្ត្រទី ២៖** កាត់បន្ថយភាពងាយរងគ្រោះតាមវិស័យ តំបន់ យេនឌ័រ និងសុខភាព នៅចំពោះមុខផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ។

**ទិសដៅយុទ្ធសាស្ត្រទី ៣៖** លើកកម្ពស់ ភាពធន់នឹងអាកាសធាតុនៃប្រព័ន្ធអេកូឡូស៊ីសំខាន់ៗ (បឹងទន្លេសាប ទន្លេមេគង្គ តំបន់ឆ្នេរ តំបន់ខ្ពង់រាប ។ល។) ជីវៈចម្រុះ តំបន់ការពារធម្មជាតិ និងតំបន់បេតិកភណ្ឌវប្បធម៌។

**ទិសដៅយុទ្ធសាស្ត្រទី ៦៖** លើកកម្ពស់ការចូលរួម និងកិច្ចគាំពារសង្គមបែបបន្សាំនឹងការប្រែប្រួលអាកាសធាតុ ដើម្បីកាត់បន្ថយការបាត់បង់ និងខូចខាត។

## ទិសដៅជាយុទ្ធសាស្ត្រទី ២៖ កាត់បន្ថយភាពងាយរងគ្រោះតាមវិស័យ តំបន់ យេនឌ័រ និងសុខភាព នៅចំពោះមុខផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ

**យុទ្ធសាស្ត្រ៖**

ក. ប្រើប្រាស់លទ្ធផល នៃការសិក្សាវាយតម្លៃដែលមានស្រាប់អំពីភាពងាយរងគ្រោះ និងហានិភ័យ ព្រមទាំងសិក្សាវាយតម្លៃជាថ្មី នៅក្នុងករណីចាំបាច់ ដើម្បីចាត់ជាអាទិភាពវិធានការបន្សាំសម្រាប់តំបន់សំខាន់ៗ នៃប្រទេសកម្ពុជា ដូចជាតំបន់ឆ្នេរ តំបន់ខ្ពង់រាប ទីជនបទ និងទីក្រុង។

ខ. អនុវត្តសកម្មភាពគន្លឹះនានា ដែលកំណត់នៅក្នុងផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ តាមវិស័យ របស់ក្រសួង-ស្ថាប័នពាក់ព័ន្ធ សម្រាប់ដោះស្រាយផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ។

គ. លើកកម្ពស់សមាហរណកម្ម ផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុកម្ពុជា ទៅក្នុងយុទ្ធសាស្ត្រជាតិ ដូចជាផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងយុទ្ធសាស្ត្រជាតិគាំពារសង្គម។

ឃ. លើកកម្ពស់វិធានការបន្សាំនឹងការប្រែប្រួលអាកាសធាតុថ្នាក់សហគមន៍ និងពង្រឹងភាពជាដៃគូរវាងរាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ សង្គមស៊ីវិល និងវិស័យឯកជន។

ង. ជំរុញការប្រើប្រាស់បច្ចេកវិទ្យាសមស្របក្នុងផលិតកម្មដំណាំ និងការចិញ្ចឹមសត្វ សម្រាប់កសិករដែលងាយរងគ្រោះ។

ច. កែលម្អប្រសិទ្ធភាពនៃការគ្រប់គ្រងវិស័យជលផល។

ឆ. កែលម្អស្ថានប្រព័ន្ធព្រៃឈើ ព្រៃលិចទឹក តំបន់ឆ្នេរ និងតំបន់ការពារធម្មជាតិ។

ជ. លើកកម្ពស់ការផលិតកៅស៊ូធម្មជាតិប្រកបដោយនិរន្តរភាព ដោយផ្តោតលើវិធានការបន្សាំ និងកាត់បន្ថយផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុ។

ឈ. លើកកម្ពស់ផលិតកម្មសត្វ និងកិច្ចការពារសុខភាពសត្វប្រកបដោយនិរន្តរភាព។

ញ. កែលម្អហេដ្ឋារចនាសម្ព័ន្ធថែទាំសុខភាព និងសមត្ថភាពរបស់បុគ្គលិកថែទាំសុខភាព ដើម្បីទប់ទល់នឹងជម្ងឺដែលបង្កដោយភ្នាក់ងារចម្លង និងជម្ងឺឆ្លងតាមទឹក នៅក្នុងបរិបទនៃការប្រែប្រួលអាកាសធាតុ។

ដ. ណែនាំពីបច្ចេកវិទ្យាអភិវឌ្ឍន៍ និងស្តារឡើងវិញនូវហេដ្ឋារចនាសម្ព័ន្ធទឹកស្អាត ដើម្បីឆ្លើយតបទៅនឹងផលប៉ះពាល់អវិជ្ជមាននៃការប្រែប្រួលអាកាសធាតុ។

ឋ. លើកកម្ពស់ការកសាងផែនការ និងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូននៅទីក្រុង ដែលត្រូវការទុនច្រើន។

ឌ. ពង្រឹងគុណភាពហេដ្ឋារចនាសម្ព័ន្ធជនបទ (ផ្លូវថ្នល់ ប្រព័ន្ធធារាសាស្ត្រ អណ្តូង និងលូដោះទឹក) ដើម្បីឱ្យធន់នឹងគ្រោះទឹកជំនន់ និងគ្រោះរាំងស្ងួត។

ឍ. លើកកម្ពស់ប្រព័ន្ធផ្តល់ព័ត៌មានជាមុនអំពីធាតុអាកាស។

ណ. ផ្តល់អាទិភាពដល់តម្រូវការរបស់ស្ត្រីនៅក្នុងការបន្សាំ និងសកម្មភាពកាត់បន្ថយការប្រែប្រួលអាកាសធាតុ។

## ទិសដៅជាយុទ្ធសាស្ត្រទី ៣៖ លើកកម្ពស់ ភាពធន់នឹងអាកាសធាតុនៃប្រព័ន្ធអេកូឡូស៊ីសំខាន់ៗ (បឹងទន្លេសាប ទន្លេមេគង្គ តំបន់ឆ្នេរ តំបន់ខ្ពង់រាប ។ល។) ជីវៈចម្រុះ តំបន់ការពារធម្មជាតិ និងតំបន់បេតិកភណ្ឌវប្បធម៌

**យុទ្ធសាស្ត្រ៖**

ក. ពង្រឹងការអភិរក្សជីវៈចម្រុះ និងស្តារប្រព័ន្ធអេកូឡូស៊ី ដែលរងការគម្រាមកំហែងពីការប្រែប្រួលអាកាសធាតុ។

ខ. លើកកម្ពស់ និងលើកទឹកចិត្តឱ្យមានដំណោះស្រាយ ដែលផ្អែកលើសហគមន៍ ផ្អែកលើប្រព័ន្ធអេកូឡូស៊ី និងអេកូទេសចរណ៍ ជាមធ្យោបាយមានប្រសិទ្ធភាពក្នុងការដោះស្រាយបញ្ហាប្រែប្រួលអាកាសធាតុ។

គ. លើកកម្ពស់ការប្រើប្រាស់ការបង់ថ្លៃសេវាប្រព័ន្ធអេកូឡូស៊ី រួមទាំងកម្មវិធីកាត់បន្ថយការបញ្ចេញឧស្ម័ន ពីការបាត់បង់ និងការរេចរឹលព្រៃឈើ (REDD+)។

ឃ. លើកកម្ពស់ការកសាងផែនការប្រើប្រាស់ដី ដោយមានការចូលរួមពីភាគីពាក់ព័ន្ធ។

## ទិសដៅជាយុទ្ធសាស្ត្រទី ៦៖ លើកកម្ពស់ការចូលរួម និងកិច្ចគាំពារសង្គមបែបបន្សាំនឹងការប្រែប្រួលអាកាសធាតុ ដើម្បីកាត់បន្ថយការបាត់បង់ និងខូចខាត

**យុទ្ធសាស្ត្រ៖**

ក. លើកកម្ពស់មីក្រូហិរញ្ញប្បទាន ដើម្បីបង្កភាពងាយស្រួលដល់សហគមន៍មូលដ្ឋាន ក្នុងការទទួលបានឥណទានសម្រាប់ធ្វើសកម្មភាពឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ។

ខ. ជំរុញ និងលើកទឹកចិត្តឱ្យមានប្រព័ន្ធធានារ៉ាប់រង សម្រាប់កាត់បន្ថយបន្ទុកហានិភ័យ និងគ្រោះមហន្តរាយអាកាសធាតុមកលើសង្គម។

គ. ធ្វើសមាហរណកម្មយេនឌ័រទៅក្នុងការកសាងផែនការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ។

ឃ. ជំរុញដំណើរការវិមជ្ឈការ ដើម្បីពង្រឹងដំណើរការហិរញ្ញវត្ថុ និងស្ថាប័នសម្រាប់ការបន្សាំនៅមូលដ្ឋាន។

ង. ចាត់ចែងជាលក្ខណៈប្រព័ន្ធសម្រាប់ការចូលរួម និងការពិគ្រោះយោបល់ជាសាធារណៈ ដែលជាចំណុចចាប់ផ្តើមសម្រាប់កសាងផែនការបន្សាំ ការលើកកម្ពស់ឱ្យអ្នកពាក់ព័ន្ធនានាបានចូលរួម ទាំងអង្គការមិនមែនរដ្ឋាភិបាល អង្គការសហគមន៍ យុវជន សហគមន៍ជនជាតិដើមភាគតិច និងវិស័យឯកជន។

ច. លើកកម្ពស់ភាពជាដៃគូរវាងវិស័យសាធារណៈ និងឯកជន រួមទាំងការទទួលខុសត្រូវចំពោះសង្គមរបស់ក្រុមហ៊ុនផងដែរ។

មីនា ២០១៤

ផលិតដោយ គណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ (គ.ជ.គ.ប.អ.)
គាំទ្រថវិកាដោយ កម្មវិធីសម្ព័ន្ធភាពប្រែប្រួលអាកាសធាតុកម្ពុជា (CCCA)
ក្រសួងបរិស្ថាន អគារលេខ ៤៨ រុក្ខវិថីព្រះសីហនុ រាជធានីភ្នំពេញ ទូរស័ព្ទ/ទូរសារ៖ (៨៥៥-២៣) ២១៨ ៣៧០
អ៊ីម៉ែល៖ admin@camclimate.org.kh គេហទំព័រ www.camclimate.org.kh

CAMBODIA CLIMATE CHANGE ALLIANCE
Implemented by: Supported by:
Ministry of Environment European Union UNDP Danida SWEDEN

# Reducing Vulnerability to Climate Change Impacts of People

## KEY FACTS ON VULNERABILITY

Cambodia is among the most vulnerable countries to climate change in Southeast Asia because of its low adaptive capacity:

- High exposure to disasters and limited coping mechanisms:
  - People exposed to flood: 1.7 millions (12.2%) people;
  - Loss and damage by Typhoon Ketsana, 2009: US$ 132 millions and 43 fatalities;
  - Loss and damage by severe flooding, 2011: US$ 520 millions plus 250 fatalities;
  - Again, Loss and damage by flooding, 2013: US$ 356 millions plus 168 fatalities;
- Highly vulnerable communes are 43%;
- Lack of clear procedure for integration of climate change in the national development plans;
- Limited capacity of the national institutions responsible for climate change and limited participation of stakeholders;
- Low adaptive capacity among citizens.




*Source: EEPSEA, 2010*

***Cambodia Climate Change Strategic Plan (CCCSP) 2014-2023 is designed to ensure strategic cohesion to address a wide range of climate change issues concerning adaptation, GHG mitigation, and low-carbon development.***

***CCCSP is the first ever comprehensive national policy document responding to climate change issues launched in November 2013.***

**CCCSP 2014-2023**

**Vision:**

**Cambodia develops towards a green, low-carbon, climate-resilient, equitable, sustainable and knowledge-based society.**

**Goal 1: Reducing vulnerability to climate change impacts of people, in particular the most vulnerable, and critical systems (natural and societal).**

**Strategic Objective2:** Reduce sectoral, regional, gender vulnerability and health risks to climate change impacts.

**Strategic Objective 3:** Ensure climate resilience of critical ecosystems (Tonle Sap Lake, Mekong River, coastal ecosystems, highlands, etc.), biodiversity, protected areas and cultural heritage sites.

**Strategic Objective 6:** Promote adaptive social protection and participatory approaches in reducing loss and damage due to climate change.

| Strategic Objective 2: | Reduce sectoral, regional, gender vulnerability and health risks to climate change impacts |
|---|---|

**Strategies:**

a. Use existing vulnerability and risk assessments, and conduct new ones where necessary, to prioritize adaptation measures for key regions of Cambodia, such as coastal zones, highlands, rural and urban areas;
b. Implement key actions identified in the SCCSPs of the line ministries for addressing climate change impacts;
c. Promote integration of the CCCSP into other national strategies such as the National Strategic Development Plan (NSDP) and the National Social Protection Strategy (NSPS);
d. Promote community-based adaptation approaches and strengthen partnerships between development partners, civil society, private sector and the government;
e. Promote the use of appropriate technologies on livestock and crop production for vulnerable farmers;
f. Improve the efficiency of the fisheries sector management;
g. Improve water and forest ecology, mangrove ecosystem, coastal zones and protected areas;
h. Promote natural rubber production in a sustainable way by focusing on both adaptation and mitigation measures;
i. Promote livestock production and protection of animal health in sustainable ways;
j. Improve healthcare infrastructure and capacity of health personnel to cope with vector-borne and water-borne diseases in the context of climate change;
k. Introduce technologies in water work development and rehabilitation in response to the negative impacts of climate change;
l. Promote capital-intensive urban transport infrastructure planning and development;
m. Enhance the quality of rural infrastructure (roads, irrigation, wells and culverts) to be resilient to flood and drought;
n. Promote early warning systems;
o. Prioritize women's needs in climate change adaptation and mitigation actions.

| Strategic Objective 3: | Ensure climate resilience of critical ecosystems (Tonle Sap Lake, Mekong River, coastal ecosystems, highlands, etc.), biodiversity, protected areas and cultural heritage sites |
|---|---|

**Strategies:**

a. Strengthen biodiversity conservation and restore ecosystems threatened by climate change;
b. Promote and encourage community-based, ecosystem-based approaches and eco-tourism as cost-effective ways of addressing climate change;
c. Promote payment for ecosystem services including REDD+;
d. Promote participatory land-use planning.

| Strategic Objective 6: | Promote adaptive social protection and participatory approaches in reducing loss and damage due to climate change |
|---|---|

**Strategies:**

a. Promote micro-financing to improve access to credits by local communities for climate change responses;
b. Promote and encourage insurance schemes for reducing climate-risk and disaster burdens on society;
c. Integrate gender into climate change response planning;
d. Leverage the decentralization process to strengthen financial and institutional processes for local adaptation;
e. Institute public engagement, participation and consultations as primary entry points for adaptation planning, promoting the involvement of multiple stakeholders including NGOs, community-based organizations (CBOs), youths, indigenous communities and the private sector;
f. Promote public-private partnership including corporate social responsibility.

March 2014

**Produced by National Climate Change Committee (NCCC)**
Financially supported by Cambodia Climate Change Alliance (CCCA)
Ministry of Environment, # 48, Samdech Preah Sihanouk Blvd., Phnom Penh, Cambodia
Phone/Fax: (855-23) 218 370, Email: admin@camclimate.org.kh
**Obtain full fact sheets from www.camclimate.org.kh**

CAMBODIA CLIMATE CHANGE ALLIANCE
Implemented by: Ministry of Environment
Supported by: European Union, UNDP, Danida, SWEDEN

# បង្វែរទៅរកមាគ៌ាអភិវឌ្ឍបៃតង តាមរយៈការលើកកម្ពស់ការអភិវឌ្ឍបញ្ចេញកាបូនតិច និងបច្ចេកវិទ្យាពាក់ព័ន្ធ

## តួលេខពិតសំខាន់ៗ នៃការអភិវឌ្ឍបញ្ចេញកាបូនតិច

ការបញ្ចេញឧស្ម័នផ្ទះកញ្ចក់របស់កម្ពុជា នៅមានកម្រិតទាបខ្លាំង បើប្រៀបធៀបនឹងតួលេខមធ្យមនៅថ្នាក់តំបន់ និងពិភពលោក។ ទោះជាយ៉ាងណាក៏ដោយ តួលេខ និងការព្យាករណ៍មួយចំនួនបង្ហាញពីនិន្នាការនៃកំណើនឧស្ម័នផ្ទះកញ្ចក់៖

- បរិមាណឧស្ម័នផ្ទះកញ្ចក់សរុបដែលកម្ពុជាបញ្ចេញនៅឆ្នាំ២០០០ មានប្រមាណ ៤៧,៦លានតោន ហើយវិស័យព្រៃឈើ បានស្រូបយកប្រមាណ ៤៨លានតោន គិតជាសមមូលឧស្ម័នកាបូនិច។
- ការផលិតអគ្គិសនីពីឥន្ទនៈហ្វូស៊ីលមាន ៩៥,២% នៃសមត្ថភាពផលិតសរុប ថាមពលវារីអគ្គិសនីមានត្រឹមតែ៣,៣% ហើយប្រភពថាមពលកើតឡើងវិញមាន១,៥%។
- អត្រាកំណើននៃយានយន្តចុះបញ្ជីមានប្រមាណ ១៩% ក្នុងមួយឆ្នាំ។
- តួលេខប៉ាន់ស្មានអំពីការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ពីវិស័យដឹកជញ្ជូន មានកំណើន ២៧% ក្នុងមួយឆ្នាំ ដែលនឹងកើនពី ៧៨៥ពាន់តោនសមមូលឧស្ម័នកាបូនិច នៅឆ្នាំ២០០០ ដល់១១.៣៧៦ពាន់តោនសមមូលឧស្ម័នកាបូនិចរហូតដល់ឆ្នាំ២០៥០។
- តម្រូវការថាមពលខ្ពស់ជាងគេតាមវិស័យ គឺវិស័យដឹកជញ្ជូន បន្ទាប់មក ផលិតកម្មអគ្គីសនី លំនៅដ្ឋាន និងឧស្សាហកម្ម។




*ប្រភព៖ ក្រសួងសាធារណការ និងដឹកជញ្ជូន ២០១៣*

*"កម្ពុជាត្រូវបង្កើនការផលិតថាមពល សំដៅជំរុញសកម្មភាពឧស្សាហកម្ម ទន្ទឹមនឹងការកែលម្អប្រសិទ្ធភាពថាមពល នៅក្នុងវិស័យដឹកជញ្ជូន និងវិស័យលំនៅដ្ឋាន ដើម្បីកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់។ នៅក្នុងដំណាក់កាលបង្កើនការផ្គត់ផ្គង់នេះ ចាំបាច់ត្រូវចាប់ផ្តើមគិតគូរអំពីការបញ្ចូលប្រភពថាមពលកកើតឡើងវិញ ទៅក្នុងផលិតកម្មថាមពល"។*

*ផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុកម្ពុជា (ផ.យ.ប.អ.ក.) ២០១៤-២០២៣ ត្រូវបានរៀបចំឡើង ដើម្បីដោះស្រាយបញ្ហាប្រែប្រួលអាកាសធាតុ តាមរយៈវិធានការបន្សុំា ការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ និងការអភិវឌ្ឍដោយបញ្ចេញកាបូនតិច។*

**ផ.យ.ប.អ.ក. ២០១៤-២០២៣**

**ចក្ខុវិស័យ**

**កម្ពុជាអភិវឌ្ឍឆ្ពោះទៅរកសង្គមមួយដែលបៃតង បញ្ចេញកាបូនតិច ធន់នឹងការប្រែប្រួលអាកាសធាតុ សមធម៌ ចីរភាព និងពឹងផ្អែកលើចំណេះដឹងជាគោល។**

**គោលបំណងទី ២៖** បង្វែរទៅរកមាគ៌ាអភិវឌ្ឍបៃតង តាមរយៈការលើកកម្ពស់ការអភិវឌ្ឍបញ្ចេញកាបូនតិច និងបច្ចេកវិទ្យាពាក់ព័ន្ធ។

**ទិសដៅយុទ្ធសាស្ត្រទី ១៖** លើកកម្ពស់ភាពធន់នឹងអាកាសធាតុ តាមរយៈការធ្វើឱ្យប្រសើរឡើងនូវសន្តិសុខស្បៀង ទឹក និងថាមពល។

**ទិសដៅយុទ្ធសាស្ត្រទី ៤៖** លើកកម្ពស់ការកសាងផែនការ និងបច្ចេកវិទ្យាបញ្ចេញកាបូនតិច ដើម្បីគាំទ្រដល់ការអភិវឌ្ឍដោយចីរភាព។

## ទិសដៅជាយុទ្ធសាស្ត្រទី ១៖ លើកកម្ពស់ភាពធន់នឹងអាកាសធាតុ តាមរយៈការធ្វើឱ្យប្រសើរឡើងនូវសន្តិសុខស្បៀង ទឹក និងថាមពល

**យុទ្ធសាស្ត្រ៖**

ក. សិក្សាវិភាគលើការរួមចំណែកនៃវិស័យពាក់ព័ន្ធក្នុងការធានាសន្តិសុខនៃប្រព័ន្ធសំខាន់ៗ។

ខ. ជំរុញ និងលើកទឹកចិត្តអ្នកពាក់ព័ន្ធ និងវិស័យនានា ឱ្យចូលរួមនៅក្នុងការកំណត់វិធានការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ។

គ. ពង្រឹងយន្តការសម្របសម្រួលសម្រាប់ការឆ្លើយតបឱ្យស៊ីសង្វាក់គ្នានៅក្នុងគោលនយោបាយឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ។

ឃ. បង្កើនសមត្ថភាពក្នុងការកំណត់រកកាលានុវត្តភាព ដែលកើតចេញពីការប្រែប្រួលអាកាសធាតុ នៅក្នុងប្រព័ន្ធផលិតកម្មកសិកម្ម ប្រព័ន្ធអេកូឡូស៊ី និងតំបន់ការពារធម្មជាតិ៖
- ពិពិធកម្មកសិកម្ម(ឧ. ដំណាំ ការចិញ្ចឹមសត្វ។ល។)
- កំណើនផលិតភាព (ឧ. ដំណាំ ជលផល ការចិញ្ចឹមសត្វ ព្រៃឈើ។ល។)
- ឱកាសសម្រាប់បង្កើនមុខដំណាំថ្មី
- ការគ្រប់គ្រងទីជម្រាល និងប្រព័ន្ធអេកូឡូស៊ី។

ង. សម្រួលដល់ធុរកិច្ច និងឧស្សាហកម្ម ដែលឆ្លើយតបទៅនឹង កាលានុវត្តភាពទីផ្សារកាបូន សម្រាប់ពាណិជ្ជកម្ម និងការវិនិយោគបៃតង។

ច. លើកកម្ពស់ថាមពលកកើតឡើងវិញ និងប្រសិទ្ធភាពថាមពល ដើម្បីកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ និងផលប៉ះពាល់សុខភាព ៖
- ថាមពលកកើតឡើងវិញ
- ប្រសិទ្ធភាពថាមពល
- ការផ្ទេរបច្ចេកវិទ្យាសមស្រប
- ការគ្រប់គ្រងសំណល់រឹង/រាវតាមវិធានការចម្រុះ នៅរាជធានី ទីក្រុង ទីប្រជុំជន និងការគ្រប់គ្រងសំណល់សត្វ។

ឆ. បង្កើតប្រព័ន្ធផលិតកម្មថាមពលវិមជ្ឈការ ដែលរួមបញ្ចូលទាំងការប្រើប្រាស់ថាមពលកកើតឡើងវិញ ជាពិសេសថាមពលព្រះអាទិត្យ។

ជ. ស្តារ និងកសាងហេដ្ឋារចនាសម្ព័ន្ធទឹក ដែលរួមទាំងប្រព័ន្ធធារាសាស្ត្រខ្នាតតូច មធ្យម និងខ្នាតធំ។

ឈ. ស្តារ និងពង្រីកហេដ្ឋារចនាសម្ព័ន្ធផ្លូវជនបទ ដែលធន់នឹងអាកាសធាតុ និងតភ្ជាប់តំបន់ផលិតកម្មទៅទីផ្សារ។

ញ. បញ្ចូលបញ្ហាប្រែប្រួលអាកាសធាតុទៅក្នុងដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន។

## ទិសដៅជាយុទ្ធសាស្ត្រទី ៤៖ លើកកម្ពស់ការកសាងផែនការ និងបច្ចេកវិទ្យាបញ្ចេញកាបូនតិច ដើម្បីគាំទ្រដល់ការអភិវឌ្ឍដោយចីរភាព

**យុទ្ធសាស្ត្រ៖**

ក. សិក្សាវិភាគទៅលើជម្រើស ដែលបញ្ចេញឧស្ម័នផ្ទះកញ្ចក់តិចនៅតាមវិស័យ និងប្រភពបញ្ចេញឧស្ម័ន (កសិកម្ម ថាមពល ការដឹកជញ្ជូន ឧស្សាហកម្ម ការគ្រប់គ្រងការប្រើប្រាស់ដី និងព្រៃឈើ និងការគ្រប់គ្រងសំណល់)។

ខ. រៀបចំគោលនយោបាយ ក្របខ័ណ្ឌច្បាប់ និងផែនការសកម្មភាពអភិវឌ្ឍន៍ដែលបញ្ចេញកាបូនតិច ដោយអនុលោមតាមអាទិភាពអភិវឌ្ឍន៍នានារបស់ជាតិ។

គ. ជំរុញការផ្ទេរបច្ចេកវិទ្យាសមស្រប ដើម្បីលើកកម្ពស់ការអភិវឌ្ឍ ដែលបញ្ចេញកាបូនតិច (ដូចជាកែលម្អប្រសិទ្ធភាពថាមពល ថាមពលកើតឡើងវិញ។ល។) និងសម្រួលឱ្យមានការប្រើប្រាស់តាមរយៈ ៖
- គោលការណ៍ណែនាំជំនួយបច្ចេកទេស និងការបង្កើតភាពជាដៃគូ
- ការលើកទឹកចិត្តផ្នែកហិរញ្ញវត្ថុ និងសារពើពន្ធ
- យន្តការទីផ្សារកាបូន
- ការកៀរគរភាពជាដៃគូសាធារណៈ និងឯកជន។

ឃ. លើកកម្ពស់ការកសាងផែនការអភិវឌ្ឍន៍ទីក្រុង ដែលធន់នឹងអាកាសធាតុ និងបញ្ចេញកាបូនតិច ព្រមទាំងបង្កើតយន្តការសម្របសម្រួលនៅកម្រិតទីក្រុង (ដូចជា ប្រព័ន្ធដឹកជញ្ជូនសាធារណៈ ដែលមានប្រសិទ្ធភាព ទំនើបកម្មអាងប្រព្រឹត្តកម្ម និងទីលានចាក់សំណល់រឹង នៅរាជធានីខេត្ត)។

ង. បង្កើតប្រព័ន្ធចុះបញ្ជីគម្រោង និងកម្មវិធីកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់។

ច. បង្កើតប្រព័ន្ធសារពើភ័ណ្ឌឧស្ម័នផ្ទះកញ្ចក់ជាតិប្រកបដោយគុណភាព។

មីនា ២០១៤

ផលិតដោយ គណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ (គ.ជ.គ.ប.អ.)
គាំទ្រថវិកាដោយ កម្មវិធីសម្ព័ន្ធភាពប្រែប្រួលអាកាសធាតុកម្ពុជា (CCCA)
ក្រសួងបរិស្ថាន អគារលេខ ៤៨ វិថីព្រះសីហនុ រាជធានីភ្នំពេញ ទូរស័ព្ទ/ទូរសារ៖ (៨៥៥-២៣) ២១៨ ៣៧០
អ៊ីម៉ែល៖ admin@camclimate.org.kh គេហទំព័រ www.camclimate.org.kh
CAMBODIA CLIMATE CHANGE ALLIANCE
Implemented by: Ministry of Environment
Supported by: European Union, UNDP, Danida, SWEDEN

# Shifting Towards a Green Development Path by Promoting Low-Carbon Development and Technologies

## KEY FACTS ON LOW-CARBON DEVELOPMENT

GHG emissions in Cambodia are currently extremely low compared to regional and global averages. However, there are increasing trends of GHGs emissions:

- In 2000, Cambodia emitted 47.6 million tonnes of $CO_2$equivalent, but forest sector absorbed 48 million tonnes of $CO_2$equivalent;
- Electricity produced by fossil fuel was (95.2%), by hydropower 3.3%, and by renewable energy 1.5%;
- Annual growth rate of vehicles registered in 2009 is 19%;
- GHGs emission from transport sector will increase from 785 $GgCO_2e$ in 2000, to 11,376 $GgCO_2e$ by 2050, a 27% increase annually;
- Highest energy consumption by sector is Transport sector, Electricity production, Residential sector Industrial sector.




*Source: Ministry of Public Works and Transport, 2013*

"Cambodia needs to increase energy production to boost industrial activities, while improving energy efficiency in the transport and residential sectors in order to reduce GHG emissions".

***Cambodia Climate Change Strategic Plan (CCCSP) 2014-2023 is designed to ensure strategic cohesion to address a wide range of climate change issues concerning adaptation, GHG mitigation, and low-carbon development.***

**CCCSP 2014-2023**

**Vision:**

**Cambodia develops towards a green, low-carbon, climate-resilient, equitable, sustainable and knowledge-based society.**

**Goal 2: Shifting towards a green development path by promoting low-carbon development and technologies.**

**Strategic Objective 1:** Promote climate resilience through improving food, water and energy security.

**Strategic Objective 4:** Promote low-carbon planning and technologies to support sustainable development.

| Strategic Objective 1: | Promote climate resilience through improving food, water and energy security |
|---|---|

**Strategies:**

a. Map sectoral contributions to the security of key systems;
b. Engage relevant sectors and stakeholders in identifying response measures;
c. Enhance institutional coordination mechanisms for coherent policy responses to climate change;
d. Increase capacity to identify climate-induced opportunities in agricultural production systems, ecosystems, and nature protected areas:
   - Agricultural diversification (e.g. crops, livestock, etc.)
   - Increase in productivity (e.g. crops, fisheries, livestock, forestry etc.)
   - Opportunity for new crop varieties
   - Watershed and ecosystem management
e. Facilitate businesses and industries which respond to carbon market opportunities for green trade and investment;
f. Promote renewable energy and energy efficiency to reduce GHG emissions and impacts on health:
   - Renewable energy
   - Energy efficiency
   - Appropriate technology transfer
   - Solid waste and wastewater management through integrated measures in capital, towns and populated areas, and animal waste management
g. Develop decentralized energy production systems integrating the application of renewable energy, especially solar energy;
h. Rehabilitate and build water infrastructures including small, medium, and large scale irrigation schemes;
i. Build and rehabilitate climate-resilient rural road infrastructures and connect production areas to the market;
j. Integrate climate change into Environmental Impact Assessment process.

| Strategic Objective 4: | Promote low-carbon planning and technologies to support sustainable development |
|---|---|

**Strategies:**

a. Conduct sectoral analyses on low emission options and sources of emission (in agriculture, energy, transportation, industrial, land-use and forest management, and waste management);
b. Prepare low-carbon development policies, legal framework and action plans in conformity with national development priorities;
c. Promote appropriate technology transfer for low-carbon development (e.g. improving energy efficiency, renewable energy, etc.) and facilitate their diffusion through:
   - Guidelines, technical assistance and establishment of partnerships
   - Financial and fiscal incentives
   - Carbon market mechanisms
   - Mobilizing public-private partner-ships
d. Promote low-carbon climate-resilient city development planning and develop city level coordination mechanisms (e.g. capital and provincial effective mass transport, modernisation of wastewater treatment facility and landfill);
e. Establish a system of registration for GHG mitigation projects and programmes;
f. Establish a high quality national system for GHG inventory.

March 2014

**Produced by National Climate Change Committee (NCCC)**
Financially supported by Cambodia Climate Change Alliance (CCCA)
Ministry of Environment, # 48, Samdech Preah Sihanouk Blvd., Phnom Penh, Cambodia
Phone/Fax: (855-23) 218 370, Email: admin@camclimate.org.kh
**Obtain full fact sheets from www.camclimate.org.kh**

CAMBODIA CLIMATE CHANGE ALLIANCE
Implemented by: Ministry of Environment
Supported by: European Union, UNDP, Danida, SWEDEN

# លើកកម្ពស់ការយល់ដឹង និងការចូលរួមរបស់សាធារណជន ក្នុងការឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ

## ទស្សនៈប្រជាជនលើការប្រែប្រួលអាកាសធាតុ

ប្រជាជនកម្ពុជាជឿថា ធាតុអាកាសកំពុងប្រែប្រួល ប៉ុន្តែនៅមានគម្លាតខ្លាំងចំពោះទស្សនៈរបស់ប្រជាជនចំពោះបាតុភូតប្រែប្រួលអាកាសធាតុ និងវិធានការឆ្លើយតប ដោយហេតុថា៖

- ប្រជាជនប្រមាណ ២៦% មិនដឹងពីរបៀបដោះស្រាយការប្រែប្រួលអាកាសធាតុនាពេលអនាគត។
- ប្រជាជន ៩៣% មិនដឹងតើស្ថាប័នណាដែលមានតួនាទីដោះស្រាយបញ្ហាប្រែប្រួលអាកាសធាតុ ចំណែក ៥២% នៃប្រជាជន ពុំបានទទួលព័ត៌មានចាំបាច់ដើម្បីឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុឡើយ។
- ទោះជាមន្ត្រីរដ្ឋាភិបាល និងអាជ្ញាធរមូលដ្ឋានមានការយល់ដឹងច្រើនចំពោះការប្រែប្រួលអាកាសធាតុ ប៉ុន្តែនៅមានទស្សនៈភាន់ច្រឡំនៅឡើយ។
- ការធ្វើសេចក្តីសម្រេចចិត្តដោយផ្អែកលើចំណេះដឹងវិទ្យាសាស្ត្រនៅមានភាពទន់ខ្សោយ។
- ប្រជាជនមានសមត្ថភាពបន្សាំទាប
- ការយល់ដឹងមានកម្រិតទាបអំពីការប្រែប្រួលអាកាសធាតុ និងជម្រើសវិធានការឆ្លើយតប។

*សមត្ថភាពឆ្លើយតបរបស់ប្រជាជនទៅនឹងការប្រែប្រួលអាកាសធាតុ*




*ប្រភព៖ ក្រសួងបរិស្ថាន ២០១១*

*ផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុកម្ពុជា (ផ.យ.ប.អ.ក.) ២០១៤-២០២៣ ត្រូវបានរៀបចំឡើង ដើម្បីដោះស្រាយបញ្ហាប្រែប្រួលអាកាសធាតុ តាមរយៈវិធានការបន្សាំ ការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ និងការអភិវឌ្ឍដោយបញ្ចេញកាបូនតិច។*

*ការបញ្ជ្រាបចំណេះដឹង និងព័ត៌មានអំពីការប្រែប្រួលអាកាសធាតុទៅក្នុងការអប់រំក្នុងប្រព័ន្ធ និងក្រៅប្រព័ន្ធ គឺជាគោលការណ៍គន្លឹះ ក្នុងការទ្រទ្រង់ការយល់ដឹងអំពីការប្រែប្រួលអាកាសធាតុ សម្រាប់កសាងសង្គមមួយ ដែលបៃតង មានសមធម៌ និងធន់ទៅនឹងអាកាសធាតុ។*

**ផ.យ.ប.អ.ក. ២០១៤-២០២៣**

**ចក្ខុវិស័យ**

**កម្ពុជាអភិវឌ្ឍឆ្ពោះទៅរកសង្គមមួយដែលបៃតង បញ្ចេញកាបូនតិច ធន់នឹងការប្រែប្រួលអាកាសធាតុ សមធម៌ ចីរភាព និងពឹងផ្អែកលើចំណេះដឹងជាគោល។**

**គោលបំណងទី ៣៖** លើកកម្ពស់ការយល់ដឹង និងការចូលរួមរបស់សាធារណជន ក្នុងការឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ។

**ទិសដៅយុទ្ធសាស្ត្រទី ៥៖** កែលម្អសមត្ថភាព ចំណេះដឹង និងការយល់ដឹងសម្រាប់ឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ។

**ទិសដៅយុទ្ធសាស្ត្រទី ៧៖** ពង្រឹងស្ថាប័ន និងក្របខ័ណ្ឌការងារសម្របសម្រួល សម្រាប់ឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុថ្នាក់ជាតិ។

**ទិសដៅយុទ្ធសាស្ត្រទី ៨៖** ពង្រឹងកិច្ចសហការ និងចូលរួមយ៉ាងសកម្ម នៅក្នុងកិច្ចខិតខំប្រឹងប្រែងឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុនៅថ្នាក់តំបន់ និងពិភពលោក។

## ទិសដៅជាយុទ្ធសាស្ត្រទី ៥៖ ពង្រឹងសមត្ថភាព ចំណេះដឹង និងការយល់ដឹងសម្រាប់ឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ

**យុទ្ធសាស្ត្រ៖**

ក. ជំរុញការអនុវត្តមាត្រាទី៦ នៃអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្ដីពីការប្រែប្រួលអាកាសធាតុ ស្ដីពីការអប់រំ ការបណ្ដុះបណ្ដាល ការយល់ដឹងជាសាធារណៈ ការចូលរួម និងការទទួលបានព័ត៌មានរបស់មហាជន និងកិច្ចសហប្រតិបត្តិការអន្តរជាតិ ក្រោមបរិបទប្រែប្រួលអាកាសធាតុ។

ខ. ពង្រឹងមធ្យោបាយដែលមានស្រាប់ សម្រាប់លើកកម្ពស់ការយល់ដឹងអំពីការប្រែប្រួលអាកាសធាតុ តាមរយៈភ្នាក់ងារផ្ដល់សេវាកម្ម រាជរដ្ឋាភិបាល គ្រូបង្រៀន អ្នកសារព័ត៌មាន សេវាកម្មផ្សព្វផ្សាយ អ្នកដឹកនាំសាសនា និងអ្នកដឹកនាំសហគមន៍។

គ. រៀបចំកម្មវិធីបង្កើនការយល់ដឹង ដោយផ្ដោតលើក្រុមគោលដៅជាក់លាក់ ដូចជាក្រុមពលរដ្ឋងាយរងគ្រោះបំផុត ស្ត្រី កុមារ យុវជន និងក្រុមជនជាតិភាគតិច។

ឃ. សម្រួលឱ្យសាធារណជនទទួលបានព័ត៌មានអំពីការប្រែប្រួលអាកាសធាតុ តាមរយៈ វិទ្យុ ទូរទស្សន៍ សារព័ត៌មាន បច្ចេកវិទ្យាចល័ត វេបសាយ និងសម្ភារៈផ្សព្វផ្សាយសម្រាប់ក្រុមគោលដៅ។

ង. ផ្សព្វផ្សាយដល់វិស័យឯកជន ឱ្យស្វែងយល់អំពីការគំរាមកំហែង និងកាលានុវត្តភាព (ជំនួយបច្ចេកទេស ថវិកា និងការផ្ទេរបច្ចេកវិទ្យា) ទាក់ទងនឹងការប្រែប្រួលអាកាសធាតុ និងបង្កើតភាពជាដៃគូសាធារណៈ និងឯកជន សម្រាប់ការប្រាស្រ័យទាក់ទង។

ច. បញ្ចូលប្រធានបទប្រែប្រួលអាកាសធាតុទៅក្នុងកម្មវិធីសិក្សានៅគ្រប់កម្រិតសិក្សា។

ឆ. ពង្រឹងគុណភាពអប់រំគ្រូបង្រៀន និងបណ្ដុះបណ្ដាលអ្នកកសាងផែនការ អំពីវិធីសាស្ត្របង្រៀន និងសិក្សារៀនសូត្រអំពីការប្រែប្រួលអាកាសធាតុ។

ជ. ពង្រឹងសមត្ថភាពក្នុងការប្រមូល វិភាគ ធ្វើម៉ូដែល និងបកស្រាយទិន្នន័យអាកាសធាតុ ហើយផ្សព្វផ្សាយព័ត៌មានអាកាសធាតុដល់អ្នកប្រើប្រាស់ផ្ទាល់ ក្នុងវិស័យនានា ដែលរួមទាំងព្យាករណ៍ប្រចាំរដូវសម្រាប់បន្សុំ និងត្រៀមសម្ភារៈប្រកាសអាសន្នជាមុនរបស់សហគមន៍ក្នុងការគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយ។

ឈ. កែលម្អប្រព័ន្ធព្យាករណ៍ និងពិនិត្យតាមដានធាតុអាកាសរបស់ជាតិ និងកសាងភាពជាដៃគូសម្រាប់បង្កើតម៉ូដែលបង្រួញមាត្រដ្ឋាន អំពីអាកាសធាតុទៅអនាគត។

ញ. បង្កើតប្រព័ន្ធផ្ដល់ព័ត៌មានអំពីធាតុអាកាសជាមុន និងកម្មវិធីសម្រាប់គ្រប់គ្រងគ្រោះមហន្តរាយ ដែលទាក់ទងនឹងអាកាសធាតុ និងការស្ដារឡើងវិញ។

ដ. ពង្រឹងតួនាទីរបស់សកលវិទ្យាល័យក្នុងការបណ្ដុះបណ្ដាល ស្រាវជ្រាវ អភិវឌ្ឍបច្ចេកវិទ្យា ដោយកសាងភាពជាដៃគូអន្តរជាតិ លើការស្រាវជ្រាវអំពីអាកាសធាតុ។

ឋ. ប្រើប្រាស់មេរៀនដែលទទួលបាន ចំណេះដឹង និងទម្លាប់ល្អៗនៅមូលដ្ឋាន សម្រាប់កសាងគោលនយោបាយ និងសកម្មភាពបន្សុំ និងកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់។

ឌ. បង្កើត "មជ្ឈមណ្ឌលគ្រប់គ្រងចំណេះដឹង" ដើម្បីសម្រួលដល់ការទទួលបានព័ត៌មានទាន់ហេតុការណ៍ដែលចាំបាច់សម្រាប់ការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ។

## ទិសដៅជាយុទ្ធសាស្ត្រទី ៧៖ ពង្រឹងស្ថាប័ន និងក្របខ័ណ្ឌការងារសម្របសម្រួល សម្រាប់ឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុថ្នាក់ជាតិ

**យុទ្ធសាស្ត្រ៖**

ក. បញ្ជ្រាបការប្រែប្រួលអាកាសធាតុ ទៅក្នុងផែនការអភិវឌ្ឍន៍ថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ និងយុទ្ធសាស្ត្រគាំពារសង្គម។

ខ. ពង្រឹងក្របខ័ណ្ឌស្ថាប័នជាតិ និងការសម្របសម្រួលអន្តរក្រសួងនៅក្នុងការកសាងគោលនយោបាយ។

គ. ពង្រឹងតួនាទី និងសមត្ថភាពរបស់លេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុសម្រាប់សម្របសម្រួលហិរញ្ញប្បទានអាកាសធាតុ និងជាស្ថាប័នជាតិសម្រាប់អនុវត្តហិរញ្ញប្បទានអាកាសធាតុពិភពលោក។

ឃ. បង្កើតក្របខ័ណ្ឌជាតិសម្រាប់ការពិនិត្យតាមដាននិងវាយតម្លៃអំពីការប្រែប្រួលអាកាសធាតុ និងរួមបញ្ចូលក្របខ័ណ្ឌនេះទៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ក៏ដូចជាផែនការយុទ្ធសាស្ត្រជាតិគាំពារ សង្គម។

ង. លើកទឹកចិត្តក្រសួងពាក់ព័ន្ធ ឱ្យកសាងយុទ្ធសាស្ត្រ និងផែនការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុតាមវិស័យ និងចូលរួមនៅក្នុងដំណើរការកសាងផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុកម្ពុជា។

## ទិសដៅជាយុទ្ធសាស្ត្រទី ៨៖ ពង្រឹងកិច្ចសហការ និងចូលរួមយ៉ាងសកម្ម នៅក្នុងកិច្ចខិតខំប្រឹងប្រែងឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុនៅថ្នាក់តំបន់ និងពិភពលោក

**យុទ្ធសាស្ត្រ៖**

ក. លើកកម្ពស់កិច្ចសហប្រតិបត្តិការថ្នាក់តំបន់ ស្ដីពីការប្រែប្រួលអាកាសធាតុ នៅក្នុងយន្តការអន្តររដ្ឋាភិបាល និងមិនមែនរដ្ឋាភិបាល៖
- ការអនុវត្តកាតព្វកិច្ចនៅក្រោមអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្ដីពីការប្រែប្រួលអាកាសធាតុ
- កិច្ចសហប្រតិបត្តិការក្រោមក្របខ័ណ្ឌអាស៊ាន
- កិច្ចសហការត្បូង-ត្បូង និងជើង-ត្បូង
- កិច្ចផ្ដួចផ្ដើមឆ្លងដែន ដូចជាក្នុងក្របខ័ណ្ឌអាងទន្លេមេគង្គ។ល។
- កិច្ចសហប្រតិបត្តិការតាមរយៈយន្តការអភិវឌ្ឍន៍ស្អាត យន្តការទីផ្សារកាបូន និងយន្តការឥណទានកាបូនពាក់ព័ន្ធនានា។

ខ. ពង្រឹងយន្តការស្ថាប័នជាតិ សម្រាប់សម្របសម្រួលការពិគ្រោះយោបល់អំពីជំហរជាតិ និងការឆ្លើយតបទៅនឹងបញ្ហាបច្ចុប្បន្ន និងអនាគត ក្នុងការចរចាជាអន្តរជាតិអំពីការប្រែប្រួលអាកាសធាតុ។

គ. ពង្រឹងជំនាញចរចារបស់កម្ពុជា ក្នុងកិច្ចចរចាអន្តរជាតិអំពីការប្រែប្រួលអាកាសធាតុ និងពង្រឹងសមត្ថភាពសម្រាប់អនុវត្តកាតព្វកិច្ចអន្តរជាតិនានា។

ឃ. ចូលរួមយ៉ាងសកម្មជាមួយកិច្ចផ្ដួចផ្ដើម និងកម្មវិធីនៅថ្នាក់តំបន់ និងកម្រិតពិភពលោក សំដៅរៀនសូត្រ ពីគ្នាទៅវិញទៅមក និងចែករំលែកជាមួយអន្តរជាតិនូវបទពិសោធន៍របស់កម្ពុជា អំពីការប្រែប្រួលអាកាសធាតុ។

ង. ធានាឱ្យមានហិរញ្ញប្បទានអាកាសធាតុពីយន្តការផ្ដល់មូលនិធិអន្តរជាតិ។

មីនា ២០១៤

ផលិតដោយ គណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ (គ.ជ.គ.ប.អ.)
គាំទ្រថវិកាដោយ កម្មវិធីសម្ព័ន្ធភាពប្រែប្រួលអាកាសធាតុកម្ពុជា (CCCA)
ក្រសួងបរិស្ថាន អគារលេខ ៤៨ វុក្ខវិថីព្រះសីហនុ រាជធានីភ្នំពេញ ទូរស័ព្ទ/ទូរសារ៖ (៨៥៥-២៣) ២១៨ ៣៧០
អ៊ីម៉ែល៖ admin@camclimate.org.kh គេហទំព័រ www.camclimate.org.kh

CAMBODIA CLIMATE CHANGE ALLIANCE
Implemented by: Supported by:
Ministry of Environment European Union UNDP Danida SWEDEN

# Promoting Public Awareness and Participation in Climate Change Response Actions

## KEY FACTS ON CLIMATE CHANGE PERCEPTION

Cambodians believe that weather is changing, yet there are significant gaps in people's understanding in climate change phenomena and response measures:

- 26% of people don't know how to cope with future climate change;
- 93% of people don't know who should take responsibility to address climate change while 52% of people do not have the information they need to respond;
- Government officials and local authority have better understanding on climate change but have some misconception;
- Weak knowledge and science-based decision making;
- Low adaptive capacity among citizens;
- Low understanding of climate change and response options.




Source: Ministry of Environment, 2011

***Cambodia Climate Change Strategic Plan (CCCSP) 2014-2023 is designed to ensure strategic cohesion to address a wide range of climate change issues concerning adaptation, GHG mitigation, and low-carbon development.***

***Mainstreaming climate change knowledge and information into formal and non-formal education is a key principle to sustaining climate change awareness for a green, equitable and climate-resilient society.***

**CCCSP 2014-2023**

**Vision:**

**Cambodia develops towards a green, low-carbon, climate-resilient, equitable, sustainable and knowledge-based society.**

**Goal 3: Promoting public awareness and participation in climate change response actions.**

**Strategic Objective 5:** Improve capacities, knowledge and awareness for climate change responses.

**Strategic Objective 7:** Strengthen institutions and coordination frameworks for national climate change responses.

**Strategic Objective 8:** Strengthen collaboration and active participation in regional and global climate change processes.

| Strategic Objective 5: | Improve capacities, knowledge and awareness for climate change responses |
|---|---|

**Strategies:**

a. Enhance the implementation of Article 6 of the UNFCCC on education, training, awareness, participation, and access to information by the people, and international cooperation for climate change response;
b. Strengthen existing channels for promoting awareness on climate change through government service providers, teachers, journalists, extension services, religious leaders and community elders;
c. Develop targeted awareness programmes aimed at key audiences such as most-vulnerable groups, women, children, youths and minorities;
d. Facilitate public access to information on climate change through radio, television, newspapers, mobile and web technologies, and targeted outreach materials;
e. Sensitize the private sector on threats and opportunities of climate change (technical support, financing, and technology transfer), and develop public-private partnerships for communication;
f. Integrate climate change into curricula for all levels of education;
g. Strengthen education quality of teachers and build capacity of planning officers on teaching and learning methodologies of climate change;
h. Strengthen the capacity for collection, analysis, modelling and interpretation of climate data and information dissemination to various end-users, including seasonal forecasting for adaptation and community early-warning facilities for disaster risk management;
i. Improve the national weather monitoring and forecasting systems, and develop partnerships for creating downscaled models of future climate;
j. Develop early-warning systems and programmes for climate-related disaster management and recovery;
k. Strengthen the role of universities in training, research and technology development by building international partnerships for climate researches;
l. Capitalize on lessons learned, local knowledge and good practices for development of policies and actions for adaptation and mitigation;
m. Develop a "knowledge management centre" for facilitating access to up-to-date information for climate change responses.

| Strategic Objective 7: | Strengthen institutions and coordination frameworks for national climate change responses |
|---|---|

**Strategies:**

a. Mainstream climate change into national and sub-national development plans and the NSPS;
b. Reinforce the national institutional framework and inter-ministerial coordination in policy development;
c. Strengthen roles and capacities of the NCCC Secretariat for coordination of climate financing and as a national implementing entity for global climate funds;
d. Develop a national monitoring and evaluation framework for climate change responses and integrate it into the NSDP and the NSPS;
e. Encourage all ministries to develop a sectoral climate change strategic plans and action plans and engage in the CCCSP process.

| Strategic Objective 8: | Strengthen collaboration and active participation in regional and global climate change processes |
|---|---|

**Strategies:**

a. Promote regional cooperation on climate change within inter-governmental and non-governmental mechanisms:
    - Implementation of commitments under the UNFCCC
    - Cooperation under ASEAN framework
    - South-South and North-South collaboration
    - Trans-boundary initiatives e.g. within the Mekong River Basin framework
    - Cooperation through Clean Development Mechanism (CDM), carbon market mechanisms and other relevant carbon credit schemes.
b. Strengthen the national institutional platform for coordinating consultation on national positions and responses to current and future issues for international negotiations on climate change;
c. Reinforce negotiation skills to effectively represent Cambodia in the international climate change processes, and improve capacity for implementation of international obligations;
d. Actively engage with regional and global initiatives and programmes for cross-learning and sharing Cambodia's experience on climate change with the international community;
e. Secure climate funds from international funding mechanisms.

*March 2014*

**Produced by National Climate Change Committee (NCCC)**
Financially supported by Cambodia Climate Change Alliance (CCCA)
Ministry of Environment, # 48, Samdech Preah Sihanouk Blvd., Phnom Penh, Cambodia
Phone/Fax: (855-23) 218 370, Email: admin@camclimate.org.kh
**Obtain full fact sheets from www.camclimate.org.kh**

CAMBODIA CLIMATE CHANGE ALLIANCE
Implemented by: Ministry of Environment
Supported by: European Union, UNDP, Danida, SWEDEN